# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២១

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 23-Apr-2021, 15:07
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

## សេចក្តីសង្ខេបរបស់ក្រុមមេធាវីការពារក្តី បន្ទាប់ពីសំណើសុំលើកពេលសវនាការលើបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី

---

ដាក់ដោយ៖

**មេធាវីការពារក្តីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

ដាក់ជូន៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Florence Ndepele MWACHANDE-MUMBA

**ជំនួយការ៖**

ក្រម ម៉ុង មុន្នីចរិយា

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

លោក តាន់ ឆាយរ័ត្ន

កញ្ញា Mathilde CHIFFERT

ចៅក្រម Maureen HARDING CLARK

ចៅក្រម យ៉ា ណារិន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោកស្រី Brenda J. HOLLIS

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

១. នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("ដើមបណ្តឹងរដ្ឋប្បវេណី") បានផ្ញើជូនអង្គជំនុំជម្រះតុលាការកំពូល ("តុលាការកំពូល") និងភាគី តាមរយៈសារអេឡិចត្រូនិច នូវសំណើសុំលើកពេលសវនាការលើបណ្តឹងសាទុក្ខ ដែលបានគ្រោងធ្វើចាប់ពីថ្ងៃទី១៧ ខែឧសភា ដល់ខែកក្កដា ឆ្នាំ២០២១។[1] ទោះស្ថិតក្នុងស្ថានភាពបន្ទាន់ និងគ្មានលទ្ធភាពក្នុងការដាក់សំណើសុំនេះឱ្យបានទាន់ស្របតាមកាលៈទេសៈក្តី[2] ក៏ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានអនុញ្ញាតឱ្យដាក់ឯកសារតែមួយភាសា ក្នុងដំណាក់កាលដំបូងឡើយ។[3]

២. នៅវេលាល្ងាច ថ្ងៃដដែលនោះ មន្ត្រីច្បាប់ជាន់ខ្ពស់នៃតុលាការកំពូល បានស្នើសុំ តាមរយៈសារអេឡិចត្រូនិច ទៅកាន់សហព្រះរាជអាជ្ញា ក្រុមមេធាវីការពារក្តី និងការិយាល័យរដ្ឋបាល ឱ្យផ្តល់ចម្លើយយ៉ាងយូរត្រឹមថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១។[4] មិនយូរប៉ុន្មាន សហព្រះរាជអាជ្ញាបានបញ្ជាក់តាមរយៈសារអេឡិចត្រូនិចថា ខ្លួននឹងដាក់ចម្លើយតប បន្ទាប់ពីទទួលបានការជូនដំណឹងពីសំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយថាខ្លួននឹងជូនដំណឹងពីជំហររបស់ខ្លួនជាផ្លូវការនៅថ្ងៃបន្ទាប់ ដោយសារតែភាពបន្ទាន់នៃសេចក្តីសម្រេចទៅលើបញ្ហានោះ។[5] ដោយឡែក ក្រុមមេធាវីការពារក្តី

[1] សារអេឡិចត្រូនិចរបស់មេធាវី HIRST ផ្ញើនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ១២ និង ៨ នាទី មានចំណងជើងថា *« Re: Lists of speakers (appeal hearing) » ដោយភ្ជាប់មកជាមួយនូវ "សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យពន្យារពេលលើសវនាការបណ្តឹងសាទុក្ខ ដែលគ្រោងធ្វើឡើងនៅថ្ងៃទី១៧-២១ ខែឧសភា ឆ្នាំ២០២១"*។ ឯកសារភ្ជាប់លេខ ១។

[2] ការឆ្លើយឆ្លងសារអេឡិចត្រូនិចរវាងលោក NILSSON និងភាគី នៅថ្ងៃទី១២ និង ១៦ ខែមេសា ឆ្នាំ២០២១ មានចំណងជើងថា *« Re: Re :Appeal hearing - (re)scheduled for 17-21 May 2021 »* (សូមមើលជាអាទិ៍ សារអេឡិចត្រូនិចរបស់មេធាវី HIRST ផ្ញើនៅថ្ងៃទី១៣ ខែមេសា វេលាម៉ោង ១២ និង ៣៤ នាទី និងថ្ងៃទី១៦ ខែមេសា វេលាម៉ោង ១២ និង ២០ នាទី)។ ឯកសារភ្ជាប់លេខ ២។

[3] សារអេឡិចត្រូនិចរបស់លោក NILSSON ផ្ញើនៅថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ១៩ និង ១១ មានចំណងជើងថា *« Re: Re :Appeal hearing - (re)scheduled for 17-21 May 2021 »*។ ឯកសារភ្ជាប់លេខ ៣។

[4] សារអេឡិចត្រូនិចរបស់លោក NILSSON ផ្ញើនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ១៧ និង ៤២ នាទី មានចំណងជើងថា *« Re: Lists of speakers (appeal hearing) »*។ ឯកសារភ្ជាប់លេខ ៤។

[5] សារអេឡិចត្រូនិចរបស់លោកស្រី HOLLIS ផ្ញើនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ១៧ និង ៥១ នាទី មានចំណងជើង

លោក ខៀវ សំផន (“មេធាវីការពារក្តី”) បានបញ្ជាក់ថា ខ្លួនមិនអាចនិយាយបានថាពេលណាអាចដាក់ចម្លើយតបបានឡើយ ដោយហេតុថាត្រូវជួបពិភាក្សាជាមួយកូនក្តីសិន ដោយគ្រាន់តែបញ្ជាក់ថាកាន់តែឆាប់គឺកាន់តែល្អ ដោយសារតែបញ្ហានានាពាក់ព័ន្ធនឹងបែបបទធ្វើដំណើររបស់លោកស្រីមេធាវីអន្តរជាតិ ក៏ដូចជាអ្នកចូលរួមដទៃទៀត ដែលមិនមានវត្តមាននៅក្នុងប្រទេសកម្ពុជា។[6]

៣. នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១ សហព្រះរាជអាជ្ញាបានជូនដំណឹងពីជំហររបស់ខ្លួន តាមរយៈសារអេឡិចត្រូនិច។ សហព្រះរាជអាជ្ញាបានកត់សម្គាល់ពីសារសំខាន់ក្នុងការដោះស្រាយបញ្ហាដែលបានលើកឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី នៅមុនពេលបើកសវនាការ និងពីទម្រង់នៃការចូលរួមដោយផ្ទាល់ពីគ្រប់ភាគី។ សហព្រះរាជអាជ្ញាក៏បានស្នើផងដែរដល់តុលាការកំពូល សុំឱ្យ “សម្រេចលើបញ្ហានេះឱ្យបានឆាប់ទោះជាក្រៅផ្លូវការ ឬផ្លូវការក្តី ដើម្បីធ្វើឱ្យមានភាពប្រាកដប្រជាទាន់ពេលវេលាចំពោះការកំណត់ពេលវេលានៃសវនាការ និងអាចឱ្យធ្វើការសម្រេចចិត្តទាន់ពេលវេលាទាក់ទងនឹងការរៀបចំការធ្វើដំណើររបស់អ្នកចូលរួមនៅក្រៅប្រទេស”។[7]

៤. នៅថ្ងៃដដែលនោះ ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំបកប្រែពាក្យបណ្តឹងរបស់ខ្លួនជាភាសាបារាំង ខណៈដែលមេធាវីការពារក្តីមិនអាចធ្វើបានទេ ដោយសារតែមិនទទួលបានការជូនដំណឹងពីសំណើសុំនេះ។

៥. ទោះបីជាមិនមានសេចក្តីជូនដំណឹង និងការបកប្រែជាភាសាខ្មែរ និងភាសាបារាំងយ៉ាងណាក្តី មេធាវីការពារក្តីគ្មានជម្រើសអ្វីផ្សេងក្រៅពីចាប់ផ្តើមតាក់តែងចាប់ពេលនេះទៅ នូវសេចក្តីសង្កេតនេះឡើង បន្ទាប់ពីសំណើសុំលើកពេលរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីឱ្យតុលាការកំពូលចេញសេចក្តីសម្រេចឱ្យបានឆាប់រហ័ស។[8] សេចក្តីសង្កេតនេះ ត្រូវបានធ្វើជូនដល់ភាគី និងមន្ត្រីច្បាប់

ថា « *Re: Lists of speakers (appeal hearing)* »។ ឯកសារភ្ជាប់លេខ ៥។

[6] សារអេឡិចត្រូនិចរបស់មេធាវី GUISSÉ ផ្ញើនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ១៩ និង ២៥ នាទី មានចំណងជើងថា « *Re: Lists of speakers (appeal hearing)* ». ។ ឯកសារភ្ជាប់លេខ ៦។

[7] សារអេឡិចត្រូនិចរបស់លោកស្រី HOLLIS ផ្ញើនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ៤ និង ៣ នាទី មានចំណងជើងថា « *Re: Lists of speakers (appeal hearing)* »។ ឯកសារភ្ជាប់លេខ ៧។

[8] សូមមើលកថាខណ្ឌបន្ទាប់ បន្ថែមលើការដែលថា ថ្ងៃចន្ទក្រោយ ទី២៦ ខែមសា ឆ្នាំ២០២១ ជាថ្ងៃបុណ្យឈប់សម្រាកកម្ពុជា។

ជាន់ខ្ពស់ តែមួយភាសា តាមរយៈសារអេឡិចត្រូនិច ហើយនឹងត្រូវដាក់ជាមួយនឹងសំណៅបកប្រែជាភាសាខ្មែរ នៅពេលទទួលបានការជូនដំណឹងអំពីសំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។

៦. តុលាការកំពូលត្រូវបានស្នើសុំឱ្យសម្រេចលើសំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណី **យ៉ាងយូរត្រឹមថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១** ទោះបីជាក្រៅផ្លូវការក៏ដោយ។ ជាក់ស្ដែង លោកស្រីមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន ត្រូវធ្វើដំណើរនៅថ្ងៃទី២៩ ខែមេសា ដើម្បីមកដល់ទីក្រុងភ្នំពេញ នៅថ្ងៃបន្ទាប់ និងត្រូវធ្វើចត្តាឡីស័កចំនួន១៤ថ្ងៃ ដើម្បីអាចចូលរួមក្នុងសវនាការ ដែលនឹងគ្រោងធ្វើនៅថ្ងៃទី១៧ ខែឧសភា។ ដោយសារការធ្វើដំណើរត្រូវបានរៀបចំឡើងស្របតាមតាមទិសដៅនេះរួចទៅហើយ ក្នុងករណីនេះ ការិយាល័យរដ្ឋបាលនៃសាលាក្ដី គួរតែមានលទ្ធភាពលុបចោលកាលបរិច្ឆេទ "យ៉ាងយូរត្រឹមថ្ងៃ២៨ ខែមេសា" ធ្វើយ៉ាងណាចៀសវាងចំណាយលើសោហ៊ុយធ្វើដំណើរនិងស្នាក់នៅដោយឥតប្រយោជន៍ ប្រសិនបើនៅទីបញ្ចប់ សវនាការនឹងមិនអាចប្រព្រឹត្តទៅបាននោះ។

៧. អាស្រ័យដោយស្ថានភាពជំងឺរាតត្បាតនៅទីក្រុងភ្នំពេញ និងវិធានការរឹតបន្តឹងរបស់រដ្ឋាភិបាល មេធាវីការពារក្ដីមិនអាចជូនដំណឹងទៅលោក ខៀវ សំផន ពីវឌ្ឍនភាពនៃរឿងក្ដីរបស់លោក ក៏ដូចជាសំណើសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលមេធាវីការពារក្ដីមិនអាចពិភាក្សាជាមួយនឹងលោកបាន។ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ មេធាវីការពារក្ដីបានចាប់ផ្ដើមនីតិវិធី ដើម្បីទទួលបានជាបន្ទាន់ នូវការអនុញ្ញាត និងការរៀបចំមធ្យោបាយទំនាក់ទំនងពីចម្ងាយជាមួយលោក ខៀវ សំផន ចំពោះមុខតុលាការកំពូល។ តុលាការកំពូលក៏បានបញ្ជូនមេធាវីការពារក្ដីទៅទាក់ទងការិយាល័យរដ្ឋបាល ការិយាល័យរដ្ឋបាលក៏បញ្ជូនទៅអង្គភាពគាំពារការការពារក្ដី។ អង្គភាពនេះក៏បានធ្វើការស្នើសុំបន្ទាន់មួយក្នុងន័យនេះ នៅថ្ងៃទី២០ ខែមេសា។ នៅពេលកំពុងតាក់តែងសារណា នេះឡើង សំណើនោះ នៅពុំទាន់បានទទួលចម្លើយតបវិញនៅឡើយ។

៨. ក្នុងលក្ខខណ្ឌនេះ **ដោយមិនអាចពិភាក្សាជាមួយនឹងលោក ខៀវ សំផន បាន** អំពីបញ្ហាកាលបរិច្ឆេទ និងបែបបទនៃសវនាការបណ្ដឹងសាទុក្ខ **មេធាវីការពារក្ដីមិនមានលទ្ធភាពឆ្លើយតប** ទៅដើមបណ្ដឹងរដ្ឋប្បវេណីឡើយ។ មេធាវីការពារក្ដីបានត្រឹមតែវាយតម្លៃខ្ពស់ទៅលើការដែលដើមបណ្ដឹងរដ្ឋប្បវេណី បានជូនដំណឹងជាសាធារណៈអំពីបញ្ហាដ៏សំខាន់បំផុតទាំងនេះ។

៩. ទោះជាយ៉ាងណា មេធាវីការពារក្តីត្រូវតែជូនព័ត៌មានដល់តុលាការកំពូល និងភាគី ឱ្យបានជ្រាបថា ក្នុងករណីលើកពេលសវនាការទៅខែមិថុនា ឬកក្កដា លោកស្រីមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន មិនអាចធានាជូនបានទេថាលោកស្រីអាចមានលទ្ធភាពធ្វើដំណើរសាជាថ្មី ដោយសារហេតុផលវិជ្ជាជីវៈផង និងហេតុផលផ្ទាល់ខ្លួនផង។ ការត្រៀមរៀបចំទាំងឡាយត្រូវបានចាត់ចែងរួចរាល់អស់ហើយ ដើម្បីឱ្យលោកស្រីមេធាវីអាចចូលរួមក្នុងសវនាការបានដោយមិនខកខាន ហើយកិច្ចការផ្ទាល់ខ្លួនផ្សេងទៀតរបស់លោកស្រី ត្រូវបានចាត់ចែង និងផ្លាស់ប្តូរទៅតាមស្ថានភាពជាក់ស្តែង។ ប្រសិនបើស្ថានភាពបច្ចុប្បន្ននៅតែបន្តអូសបន្លាយទៅមុខ ការធ្វើដំណើរមកប្រទេសកម្ពុជាតម្រូវឱ្យធ្វើចត្តាឡីស័កយ៉ាងតឹងរ៉ឹងចំនួន១៤ថ្ងៃ នៅពេលធ្វើដំណើរមក និងយ៉ាងតិចក៏មួយសប្តាហ៍ដែរ នៅពេលធ្វើដំណើរត្រឡប់ទៅវិញ គឺមានន័យថា ជាក់ស្តែង លោកស្រីត្រូវចំណាយពេលសរុបមួយខែ សម្រាប់ចូលរួមក្នុងសវនាការរយៈពេលមួយសប្តាហ៍។ ទោះបីជាមេធាវីការពារក្តីដឹងច្បាស់ថា ស្ថានភាពពិសេសនេះ មិនមែនជាក្តីកង្វល់របស់តុលាការកំពូល តែវាជាកង្វល់ធំមួយរបស់លោក ខៀវ សំផន និងសម្រាប់ការរៀបចំក្រុមការងារនៃមេធាវីការពារក្តី។ ការមិនអាចពិភាក្សាជាមួយលោក វាកាន់តែចោទជាបញ្ហាថែមទៀត។ ពីព្រោះថា ដោយសារថ្ងៃឈប់សម្រាកបុណ្យចូលឆ្នាំខ្មែរ និងការបិទខ្ទប់ផង លោកដឹងតែត្រឹមថាកាលបរិច្ឆេទនៃការពិភាក្សាដេញដោលត្រូវបានកំណត់ ពីថ្ងៃទី១៧ ដល់ថ្ងៃទី២១ ខែឧសភា ដោយមានវត្តមាននៃមេធាវីទាំងពីររូបរបស់លោកនៅក្នុងសវនាការ។

១០. ម៉្យាងវិញទៀត មេធាវីការពារក្តីសូមឆ្លៀតឱកាសនេះរំឭកផងដែរថា តុលាការកំពូលនៅពុំទាន់បានជូនដំណឹងនៅឡើយអំពីកាលវិភាគនៃកិច្ចពិភាក្សាដេញដោល (ប្រធានបទ និងថិរវេលាធ្វើអន្តរាគមន៍) ព្រមទាំងបញ្ហាដែលអង្គជំនុំជម្រះមានបំណងឱ្យភាគីផ្តោតការយកចិត្តទុកដាក់នៅក្នុងសវនាការ បន្ទាប់ពីសេចក្តីសង្កេតរបស់ភាគី ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១។[9] **ទោះបីជាសវនាការ**

---

[9] តុលាការកំពូលបាន "ជូនដំណឹងភាគីថា ដីកាកំណត់កាលបរិច្ឆេទសវនាការនឹងត្រូវចេញឆាប់ៗបន្ទាប់ពីមានការសម្រេចលើកាលវិភាគស្ថាពរ និងការកំណត់នូវសំណួរជាក់លាក់ដែលរំពឹងទុកថា សារណាផ្ទាល់មាត់របស់ភាគីនឹងផ្តោតទៅលើនោះ។ (ការអញ្ជើញដាក់សេចក្តីសង្កេតលើកាលវិភាគសម្រាប់សវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០២១ ទំព័រ ៣ យើងគូសបន្ទាត់ពីក្រោម)។

**ត្រូវបាន ឬមិនបានលើកពេលយ៉ាងណាក្តី** វាជាការសំខាន់បំផុតដែលភាគីត្រូវទទួលបានព័ត៌មាន **ឱ្យបានឆាប់បំផុតតាមតែអាចធ្វើទៅបាន** សម្រាប់ការត្រៀមរៀបខ្លួន និងជាពិសេស ចំពោះមេធាវីការពារក្តី ដែលត្រូវឆ្លើយតបផងដែរទៅភាគីផ្សេងទៀត ។

១១. **<u>អាស្រ័យហេតុនេះ</u>** មេធាវីការពារក្តីសូមស្នើអង្គជំនុំជម្រះតុលាការកំពូលមេត្តា**សម្រេចលើ**សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី **យ៉ាងយូរត្រឹមថ្ងៃទី២៨ ខែមេសា** និង**ជូនដំណឹង**ឱ្យបានឆាប់បំផុត ពីកាលវិភាគនៃកិច្ចពិភាក្សាដេញដោលនៅក្នុងសវនាការ ព្រមទាំងសំណួរដែលលោកចៅក្រមសួរទៅកាន់ភាគី ទោះបីជាលក្ខណៈក្រៅផ្លូវការក៏ដោយ។

| | | |
|---|---|---|
| មេធាវី **គង់ សំអុន**<br><br>មេធាវី **Anta GUISSÉ** | ទីក្រុងភ្នំពេញ<br><br>ទីក្រុងប៉ារីស | |